Forte
General Insurance

# AUTOMOBILE INSURANCE CLAIM PROCEDURES

RED Team | Emergency Assistance
078 336 999 / 023 888 080

This is the Details of Claim Procedures for Automobile Insurance which is to provide you with general information about the procedures that need to be followed when you need to claim under your Automobile Insurance Policy.

For specific terms and conditions, please read the Insurance Policy of your vehicle in order to know the coverage, exclusions, conditions, and other provisions of the Policy as well as the obligations you need to fulfill in making a claim.

When an accident occurred, you have the following obligations:

## STEP 1: LOSS NOTIFICATION

- When an accident occurred, you must keep your vehicles at the accident site,[1] then immediately notify FORTE via 24/7 Hotline Number at 023 888 080 or 078 336 999. In any case, this notification cannot be made later than 24 hours after the accident occurred. **FORTE is not liable to pay claim if this notification was not made within 24 hours at the latest.**
- In case of loss of vehicle caused by theft, in addition to the obligation of notifying FORTE about the loss, clients must immediately file a complaint to a local police authority. In any case, this filing cannot be made later than 24 hours after the loss occurred.

  **FORTE is not liable to pay the claim if this complaint was not made to the police within 24 hours at the latest.**

## STEP 2: ARRIVAL AT THE ACCIDENT SITE

- After receiving the notification,
  - Our RED Team will try to arrive at the accident site within 30 minutes2 at the latest if the accident occurs in Phnom Penh, Kampong Cham, Siem Reap, Battambang, Kampong Spue and Sihanouk Ville.
  - If the accident occurs in other places, our RED Team will advise you about what you should do before they arrive.
- When RED Team arrives at the accident site, they will inspect the situation of the accident. They will require:
  - Detailed cause of how the accident happens (please provide your best cooperation);
  - Driving License of the Driver; and
  - Yellow Insurance Certificate (លតាបត្រធានារ៉ាប់រង) which is sticked on the Vehicle's windshield or any part of the Vehicle
  - Other documents you may be carrying with.
- Then, RED Team will settle the case with the affected third party(ies) on behalf of you.

**Notes:**

❖ **Drivers are obligated to keep the Driving Licenses[3] with them and show it to our RED Team when requested.** In case the Drivers do not bring the Driving Licenses with them, our RED Team will negotiate with third party(ies) on behalf of you, but you must bear all expenses that may incur. FORTE will reimburse you those expenses when the proper Driving License and other supporting documents are submitted to Forte.

❖ FORTE suggests that you stick the Yellow Insurance Certificate (លតាបត្រធានារ៉ាប់រង) provided by FORTE onto your vehicle's windshield for our RED Team to work faster. If possible, please also keep a copy of your insurance documents in the vehicle for our verification in any event of accident especially at night or on holidays.

❖ It is a Condition under your insurance policy that you must not admit any responsibility or make any offer, compromise, or payment without our permission. **FORTE will be entitled to refuse your claim if you fail to comply with this Condition.**

[1] Escaping from the accident site is an illegal act (Art. 35 & 38 of the Law on Road Traffic). If you are concerned about your safety, you may drive the vehicle to the nearest police station.
[2] In some cases, our RED Team may arrive at the accident site later than 30 minutes if there is traffic congestion.
[3] Cambodia recognizes the International Driving Licenses as long as the country of the holder is a party to the 1949 Road Traffic Convention (Art. 45 of the Road Traffic Law).

## STEP 3: DOCUMENT SUBMISSION

- After the accident, you must provide the following documents to FORTE as soon as possible:

| | | |
|---|---|---|
| 1. | Claim Form (with signature and stamp)[4] | 01 copy |
| 2. | A copy of Driving License | 01 copy |
| 3. | A copy of Vehicle Registration Card | 01 copy |
| 4. | If you settle the case by yourself; but with an agreement from FORTE: | |

   - Photos of the accident including Photos of the site, photos of all the vehicles involved, photos of all third party(ies) and other people involved in the accident who have sustained bodily injuries, etc.
   - Settlement Agreement with Third party(ies)
   - Police Report

5. Other relevant documents, if any.

- Please submit the Documents to FORTE to the following address:

| | |
|---|---|
| **FORTE Insurance (Cambodia) Plc.**<br>Vattanac Capital, Level 18, No.66 Monivong Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh City, Kingdom of Cambodia. | **Tel** : (+855) 23 885 077 / 066<br>**Fax** : (+855) 23 986 922 / 882 798<br>**Email** : claims@forteinsurance.com |

- Late submission of documents to FORTE will result in the delay of your claim payment.

## STEP 4: VEHICLE REPAIR

- After the accident, you must maintain your vehicles in order for our RED Team to inspect the extent of damage and advise which garage the damaged vehicle should be brought for repair.
- Bringing the damaged vehicle for repair at any repairer by yourself without FORTE's prior consent is strictly prohibited. **FORTE will be entitled to refuse your claim if you fail to comply with this Condition.**
- After the repair work is done:
   - If the damaged vehicle is repaired by our Panel Garage, you are obligated to check the vehicle thoroughly and inform FORTE if any part needs to be further repaired. FORTE will request the Panel Garage to repair that part if your request is reasonable.
   - If the damaged vehicle is repaired by other garages at your choice, FORTE will not coordinate with the garage for or be responsible for any unsatisfactory result of the repair.

## STEP 5: DEDUCTIBLE

- After the repair is done, you are obligated to pay to Forte **Deductible/Co-insurance** as stated in your Policy Schedule when you get the vehicle from our Panel Garage, unless agreed otherwise.

| IMPORTANT REMINDER | MODIFICATION |
|---|---|
| Driving with the respect to the Law on Road Traffic prevents accident on yourself and others. FORTE will be entitled to refuse your claim if the accident occurs under any of the following circumstances:<br>- Driving under the influence of alcohol (0.25 mg per liter of air) or drug<br>- Driver has no Driving License or holds a wrong type of Driving License[5] or invalid Driving License<br>Intentionally driving to cause an accident to yourself or third party. | These procedures are subject to change depending on change of law and other regulations of Cambodia, your specific insurance Policy, change of FORTE's Underwriting philosophy, etc. (this is not an exhaustive list of change which may arise from time to time.)<br>FORTE will inform you through all possible means if there is any change. |

[4] For you as an individual person, the stamp is not required.
[5] For vehicle bearing Military or Police Plate number, drivers must hold the Driving License which is issued by Ministry of National Defense or Ministry of Interior (Art. 39 of the Law on Road and Traffic).

Forte
General Insurance

# ធានារ៉ាប់រងលើយានយន្ត
## នីតិវិធីទាមទារសំណង

RED Team | Emergency Assistance
078 336 999 / 023 888 080

នេះជាព័ត៌មានលម្អិតអំពីនីតិវិធីនៃការទាមទារសំណងសម្រាប់ធានារ៉ាប់រងលើយានយន្ត ដែលមានគោលបំណងផ្តល់ជាព័ត៌មានទូទៅដល់លោកអ្នក អំពី **នីតិវិធី**ដែលលោកអ្នកត្រូវប្រតិបត្តិតាមនៅពេលលោកអ្នកត្រូវការទាមទារសំណង នៅក្រោមបណ្ណសន្យារ៉ាប់រងលើយានយន្តរបស់លោកអ្នក។

សម្រាប់ខ និង លក្ខខណ្ឌជាក់លាក់ សូមអាន បណ្ណសន្យារ៉ាប់រងនៃយានយន្តរបស់លោកអ្នក ដើម្បីដឹងពីវិសាលភាពធានារ៉ាប់រង ករណីមិនធានា លក្ខខណ្ឌ និងបទប្បញ្ញត្តិ ផ្សេងៗនៃបណ្ណសន្យារ៉ាប់រង ព្រមទាំង កាតព្វកិច្ចដែលលោកអ្នកត្រូវបំពេញនៅពេលទាមទារសំណង ។

នៅពេលមានគ្រោះថ្នាក់យានយន្តណាមួយបានកើតឡើង លោកអ្នក ត្រូវបំពេញកាតព្វកិច្ចទាំងឡាយដូចខាងក្រោមនេះ៖

### ជំហ៊ានទី ១៖ ការជូនដំណឹង

- នៅពេលមានគ្រោះថ្នាក់កើតឡើង លោកអ្នកត្រូវទុកយានយន្តនៅកន្លែងកើតហេតុ[1] ហើយទាក់ទងមកក្រុមហ៊ុនហ្វតេ ភ្លាមតាមប្រព័ន្ធទូរស័ព្ទសេវា ២៤ ម៉ោង/៧ ថ្ងៃ លេខ **០២៣ ៨៨៨ ០៨០ ឬ ០៧៨ ៣៣៦ ៩៩៩**។ ក្នុងករណីណាក៏ដោយ ការជូនដំណឹងនេះមិនអាចហួសពី **២៤** ម៉ោង ក្រោយពីពេលគ្រោះថ្នាក់បានកើតឡើងឡើយ។ **ក្រុមហ៊ុនហ្វតេ នឹងបដិសេធមិនទទួលខុសត្រូវលើការផ្តល់សំណងទេ ប្រសិនបើការជូនដំណឹងនេះមិនត្រូវបានធ្វើឡើងក្នុងអំឡុង ពេល ២៤ ម៉ោង យ៉ាងយូរ។**

- ក្នុងករណីមានការបាត់បង់យានយន្តដោយអំពើចោរកម្ម បន្ថែមពីលើកាតព្វកិច្ចជូនដំណឹងមកក្រុមហ៊ុនហ្វតេ អតិថិជនត្រូវដាក់ពាក្យបណ្តឹង ទៅសមត្ថកិច្ចប៉ូលីសមូលដ្ឋានភ្លាម។ ក្នុងករណីណាក៏ដោយ ការដាក់ពាក្យបណ្តឹងនេះមិនត្រូវធ្វើហួសពី **២៤** ម៉ោង ក្រោយពីពេលហេតុការណ៍បានកើតឡើងឡើយ។ **ក្រុមហ៊ុនហ្វតេ នឹងបដិសេធមិនទទួលខុសត្រូវលើការផ្តល់សំណងទេ ប្រសិនបើការដាក់ពាក្យបណ្តឹងនេះមិនត្រូវបានធ្វើឡើងក្នុងអំឡុង ពេល ២៤ ម៉ោង យ៉ាងយូរ។**

### ជំហ៊ានទី ២៖ ការចុះទៅកន្លែងកើតហេតុ

- ក្រោយពេលទទួលដំណឹងអំពីគ្រោះថ្នាក់នេះ
  - ក្រុមដោះស្រាយសំណងRED របស់យើង នឹងព្យាយាមទៅដល់កន្លែងកើតហេតុក្នុងរយៈពេល ៣០ នាទី[2] យ៉ាងយូរ ប្រសិនបើគ្រោះថ្នាក់នោះកើតឡើងក្នុងរាជធានីភ្នំពេញ កំពង់ចាម សៀមរាប បាត់ដំបង ព្រះសីហនុ។
  - ប្រសិនបើគ្រោះថ្នាក់នោះ កើតឡើងក្នុងខេត្តផ្សេង ក្រុមដោះស្រាយសំណងRED របស់យើង នឹងផ្តល់យោបល់ទៅកាន់លោកអ្នកពីអ្វីដែលលោកអ្នកត្រូវធ្វើ ទំរាំដល់ពេលដែលពួកគាត់ទៅដល់។
- នៅពេលក្រុមដោះស្រាយសំណងRED ទៅដល់កន្លែងកើតហេតុ គាត់នឹងពិនិត្យស្ថានភាពនៃគ្រោះថ្នាក់។ ពួកគាត់នឹងត្រូវការ៖
  - ព័ត៌មានលម្អិតពីដើមហេតុនៃគ្រោះថ្នាក់ (សូមមេត្តាសហការណ៍ក្នុងការផ្តល់ព័ត៌មាននេះ)
  - ប័ណ្ណបើកបររបស់អ្នកបើកបរយានយន្ត និង
  - លតាបត្រធានារ៉ាប់រង (លតាបត្រពណ៌លឿង) ដែលបិទនៅលើកញ្ចក់មុខ ឬផ្នែកណាមួយនៃយានយន្ត
  - ឬឯកសារផ្សេងទៀតដែលលោកអ្នក មានជាប់ខ្លួន
- បន្ទាប់មក ក្រុមដោះស្រាយសំណងRED នឹងដោះស្រាយជាមួយតតិយជន ជំនួសឲ្យលោកអ្នក។

**Notes:**

- **អ្នកបើកបរមានកាតព្វកិច្ចរក្សាប័ណ្ណបើកបរ[3]របស់ខ្លួនតាមខ្លួន និងបង្ហាញវាទៅក្រុមដោះស្រាយសំណងRED របស់ក្រុមហ៊ុនហ្វតេតាមការស្នើសុំ។** ក្នុងករណីអ្នកបើកបរមិនមានប័ណ្ណបើកបរជាប់ខ្លួន **ក្រុមដោះស្រាយសំណងRED** នឹងចរចារជាមួយភាគីតតិយជនជំនួសលោកអ្នក ប៉ុន្តែការចំណាយនានានឹងជាបន្ទុករបស់លោកអ្នក។ ក្រុមហ៊ុនហ្វតេនឹងធ្វើការទូទាត់ការចំណាយនេះទៅលោកអ្នកវិញ នៅពេលដែលលោកអ្នកប្រគល់ប័ណ្ណបើកបរ និងឯកសារគំរូនានាមកក្រុមហ៊ុនហ្វតេ ហើយក្រុមហ៊ុនហ្វតេពិនិត្យឃើញថាឯកសារទាំងនោះមានភាពត្រឹមត្រូវ។
- ក្រុមហ៊ុនហ្វតេ ស្នើសុំឲ្យលោកអ្នកបិទ**លតាបត្រធានារ៉ាប់រង (លតាបត្រពណ៌លឿង)** ដែលក្រុមហ៊ុនហ្វតេផ្តល់ជូន លើកញ្ចក់មុខនៃយានយន្ត ដើម្បី**ក្រុមដោះស្រាយសំណងRED** ធ្វើការកាន់តែ ឆាប់រហ័ស។ ប្រសិនបើអាច សូមរក្សាទុកច្បាប់ថតចម្លងឯកសារធានារ៉ាប់រងចំនួន ០១ ច្បាប់ នៅក្នុងយានយន្តរបស់លោកអ្នក សំរាប់ការផ្ទៀងផ្ទាត់ក្នុងករណីគ្រោះថ្នាក់ ជាពិសេសនៅពេលដែលគ្រោះថ្នាក់កើតឡើងនៅពេលយប់ ឬថ្ងៃឈប់

[1] ការបើកយានយន្តគេចពីកន្លែងកើតហេតុជាអំពើល្មើសមាត្រា ៣៥ និងមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ ក្នុងករណីមានការបារម្ភណ៍ពីសុវត្ថិភាព លោកអ្នកអាចបើករថយន្តទៅកាន់ប៉ុស្តិ៍ប៉ូលីសដែលនៅជិតបំផុតបាន។
[2] ក្នុងករណីខ្លះ ក្រុមដោះស្រាយសំណងRED របស់យើងអាចទៅដល់ទីតាំងកើតហេតុយឺតយូរជាង៣០នាទី ប្រសិនបើមានការកកស្ទះចរាចរណ៍។
[3] ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ប័ណ្ណបើកបរអន្តរជាតិឲ្យតែប្រទេសនោះជាសមាជិកអនុសញ្ញាអន្តរជាតិ ឆ្នាំ១៩៤៩ ស្តីពីចរាចរណ៍ផ្លូវគោក (មាត្រា ៤៥ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក)។

សម្រាក។

- ប័ណ្ណសន្យារ៉ាប់រងរបស់លោកអ្នក មានលក្ខខ័ណ្ឌ១ដែលបានចែងថា **លោកអ្នកមិនត្រូវទទួលយកនូវទំនួលខុសត្រូវណាមួយ ឬយល់ព្រមផ្តល់អ្វីមួយ ឬ យល់ព្រមផ្តល់ការសម្របសម្រួល ឬ យល់ព្រមបង់ទូទាត់សំណងទៅតតិយជន ដោយមិនបានទទួលការឯកភាពពីក្រុមហ៊ុនហ្វតតេជាមុនឡើយ** ។ ក្រុមហ៊ុនហ្វតតេ មានសិទ្ធក្នុងការបដិសេធ ការទាមទារសំណងរបស់លោកអ្នក ប្រសិនបើលោកអ្នកមិនបានគោរពតាមលក្ខខណ្ឌនេះ។

## ជំហ៊ានទី ៣៖ ការផ្តល់ឯកសារ

- ក្រោយពេលគ្រោះថ្នាក់ លោកអ្នកត្រូវផ្តល់ឯកសារដូចខាងក្រោមមកក្រុមហ៊ុនហ្វតតេឲ្យបានលឿនបំផុតតាមដែលអាចធ្វើបាន៖

| | | |
|---|---|---|
| ១ | បែបបទទាមទារសំណង (ដែលមានហត្ថលេខា និងបោះត្រា) [4] | ០១ ច្បាប់ |
| ២ | ច្បាប់ចម្លង ប័ណ្ណបើកបរ | ០១ ច្បាប់ |
| ៣ | ច្បាប់ចម្លង ប័ណ្ណសម្គាល់យានយន្ត | ០១ ច្បាប់ |
| ៤ | ក្នុងករណីដែលលោកអ្នកបានដោះស្រាយដោយខ្លួនឯង ប៉ុន្តែមានការឯកភាពពីក្រុមហ៊ុនហ្វតតេ៖<br>៤.១ រូបថតនៃករណីគ្រោះថ្នាក់ រួមមាន រូបថតនៃកន្លែងកើតហេតុ រូបថតនៃយានយន្តដែលពាក់ព័ន្ធ រូបថតនៃតតិយជននិងភាគីពាក់ព័ន្ធផ្សេងទៀតដែលមានរបួស ជាដើម<br>៤.២ កិច្ចព្រមព្រៀងជាមួយតតិយជន<br>៤.៣ របាយការប៉ូលីសចរាចរណ៍ | |
| ៥ | ឯកសារពាក់ព័ន្ធផ្សេងៗទៀតប្រសិនជាមាន | |

- សូមផ្ញើឯកសារខាងលើមកក្រុមហ៊ុនហ្វតតេ តាមរយៈអាសយដ្ឋានខាងក្រោម៖

| | |
|---|---|
| **ក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ**<br><br>អគាររឌ្ឍន: ជាន់ទី១៨ អគារលេខ ៦៦ មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | **ទូរសព្ទ** : (+៨៥៥) ២៣ ៨៨៥ ០៧៧/ ០៦៦<br>**ទូរសារ** : (+៨៥៥) ២៣ ៩៨៦ ៩២២ / ៨៨២ ៧៩៨<br>**សារអេឡិចត្រូនិច** : auto_claims@forteinsurance.com |

- ការផ្ញើឯកសារមកក្រុមហ៊ុនហ្វតតេយឺតយ៉ាវ នឹងនាំឲ្យមានការពន្យាពេលការទូទាត់សំណងរបស់លោកអ្នក។

## ជំហ៊ានទី ៤៖ ការជួសជុលយានយន្ត

- ក្រោយពេលគ្រោះថ្នាក់ លោកអ្នកត្រូវថែរក្សាយានយន្ត ដើម្បីឲ្យ**ក្រុមដោះស្រាយសំណងRED**ពិនិត្យពីវិសាលភាពនៃការខូចខាត និងសម្រេចថាតើត្រូវយកយានយន្តនោះទៅជួសជុលនៅយានដ្ឋានមួយណា។
- ការយកយានយន្តទៅជួសជុលនៅយានដ្ឋានណាមួយដោយខ្លួនឯង ដោយមិនមានការ ឯកភាពជាមុនពីក្រុមហ៊ុនហ្វតតេ ត្រូវបានហាមឃាត់ ជាដាច់ខាត។ **ក្រុមហ៊ុនហ្វតតេនឹងបដិសេធមិនទទួលខុសត្រូវលើការផ្តល់សំណងទេ ប្រសិនបើអតិថិជនមិនបានគោរពលក្ខខណ្ឌនេះ។**
- នៅពេលយានយន្តត្រូវបានជួសជុលរួចរាល់ហើយ
  - ក្នុងករណីការជួសជុលត្រូវបានធ្វើឡើងដោយយានដ្ឋានដៃគូររបស់ក្រុមហ៊ុនហ្វតតេ លោកអ្នកមានកាតព្វកិច្ចពិនិត្យមើលយានយន្តលោកអ្នកឲ្យបានល្អិតល្អន់ និងត្រូវជូនដំណឹងមកក្រុមហ៊ុនហ្វតតេប្រសិនបើមានចំណុចណាមួយត្រូវជួសជុលបន្ថែម។ ក្រុមហ៊ុនហ្វតតេនឹងស្នើរឲ្យយានដ្ឋានជួសជុលចំណុចនោះបន្ថែម ប្រសិនបើ ការទាមទាររបស់លោកអ្នកមានលក្ខណ:សមហេតុផល។
  - ក្នុងករណីការជួសជុលត្រូវបានធ្វើឡើងនៅយានដ្ឋានដែលមិនមែនជាដៃគូររបស់ក្រុមហ៊ុនហ្វតតេ ដែលលោកអ្នកជាអ្នកជ្រើសរើសយានដ្ឋាននោះដោយខ្លួនឯង ក្រុមហ៊ុនហ្វតតេនឹងមិនអាចសម្របសម្រួលជាមួយយានដ្ឋាននោះ ឬទទួលខុសត្រូវចំពោះលទ្ធផលនៃការជួសជុលនោះឡើយ ប្រសិនបើការជួសជុលនោះមិនបានបំពេញតាមបំណងរបស់លោកអ្នក។

## ជំហ៊ានទី ៥៖ កម្រិតមិនទូទាត់សំណង

- នៅពេលយានយន្តត្រូវបានជួសជុលរួចរាល់ហើយ លោកអ្នកមានកាតព្វកិច្ចបង់មកក្រុមហ៊ុនហ្វតតេនូវ **កម្រិតមិនទូទាត់សំណង** (**Deductible/Co-insurance**) ដូចដែលមានចែងនៅក្នុងតារាងសន្យារ៉ាប់រងរបស់លោកអ្នក នៅពេលលោកអ្នកទទួលយកយានយន្តរបស់លោកអ្នក យានដ្ឋានដៃគូររបស់ក្រុមហ៊ុនហ្វតតេ លើកលែងតែមានការឯកភាពគ្នាផ្សេងពីនេះ។

[4] សម្រាប់លោកអ្នកជារូបវន្តបុគ្គល ត្រាក្រុមហ៊ុននេះមិនត្រូវបានតម្រូវឲ្យមានទេ។

| ការក្រើនរំលឹកសំខាន់ | ការកែប្រែ |
|---|---|
| ការបើកបរដោយគោរពច្បាប់ចរាចរណ៍គឺជាការចូលរួមបង្ការមិនឲ្យមានគ្រោះថ្នាក់កើតឡើងចំពោះខ្លួន និងអ្នកដទៃ។ ក្រុមហ៊ុនហ្វតតេ មានសិទ្ធក្នុងការបដិសេធ ការទាមទារសំណងរបស់លោកអ្នក ប្រសិនបើគ្រោះថ្នាក់បានកើតឡើងក្នុងករណីណាមួយដូចខាងក្រោម៖<br>- ការបើកបរក្រោមឥទ្ធិពលជាតិស្រវឹង (០.២៥ មីលីក្រាម ក្នុងមួយលីត្រខ្យល់) ឬគ្រឿងញៀន<br>- អ្នកបើកបរមិនមានប័ណ្ណបើកបរ ឬមានប័ណ្ណបើកបរខុសប្រភេទយានយន្ត[5] ឬប័ណ្ណបើកបរអស់សុពលភាព<br>- ការបើកបរបង្ករគ្រោះថ្នាក់ដោយខ្លួនឯង ឬលើអ្នកដទៃដោយចេតនា[6] | នីតិវិធីទាមទារសំណងខាងលើនេះ អាចនឹងមានការកែប្រែ អាស្រ័យលើការកែប្រែរបស់ច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា កិច្ចសន្យាធានារ៉ាប់រងជាក់លាក់ណាមួយរបស់លោកអ្នក ការកែប្រែទស្សនៈវិស័យនៃការវាយតំលៃហានិភ័យធានារ៉ាប់រងរបស់ក្រុមហ៊ុនហ្វតតេ ។ល។<br><br>ក្រុមហ៊ុនហ្វតតេនឹងជូនដំណឹងទៅកាន់លោកអ្នក តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន ប្រសិនបើមានការកែប្រែណាមួយ។ |

[5] ចំពោះយានយន្តផ្លាកលេខ **ខេមរភូមិន្ទឬនគរបាល** អ្នកបើកបរយានយន្តនេះត្រូវកាន់ប័ណ្ណបើកបរដែលចេញដោយក្រសួងការពារជាតិ ឬក្រសួងមហាផ្ទៃ (មាត្រា៣៩ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក)។
[6] ការបើកបរបញ្ច្រាសទិសលើផ្លូវឯកទិសហើយបង្ករឲ្យមានគ្រោះថ្នាក់ចរាចរណ៍កើតឡើងអាចត្រូវបានចាត់ទុកថាជាការបង្ករគ្រោះថ្នាក់ដោយចេតនា។